ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ: ០៥០ ប្រក កសក

# ប្រកាស

## ស្តីពី

## គំរូសំណាបិនភ្ជិតលើខុនថែនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/ករម/០១៩៦/១៣ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើ ច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/ករម/០៨០២/០១៦ ចុះថ្ងៃទី ៣១ ខែសីហា ឆ្នាំ ២០០២ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី ០៧ ខែមេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្ត ទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ១១ ខែកញ្ញា ឆ្នាំ ២០០៣ ស្តីពីការប្តូរឈ្មោះ នាយកដ្ឋាន រុក្ខា-ប្រមាញ់ ទៅជារដ្ឋបាលព្រៃឈើ
- បានឃើញប្រកាសលេខ ៥០៩ ប្រក.កសក.ប្ញ ចុះថ្ងៃទី ១៧ ខែកញ្ញា ឆ្នាំ២០០៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលព្រៃឈើ
- បានឃើញការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ ១ :** ប្រកាសនេះ កំណត់ការបង្កើត ការប្រើប្រាស់គំរូសំណបិទភ្ជិត និងនីតិវិធីនៃការត្រួតពិនិត្យ និងកិបសំណបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ ដើម្បីធានាបាននូវការគ្រប់គ្រង និងទទួលខុសត្រូវរបស់រដ្ឋបាលព្រៃឈើក្នុងការនាំចេញផល អនុផលព្រៃឈើ ប្រកបដោយប្រសិទ្ធិភាព ។

**ប្រការ ២ :** អនុញ្ញាតឱ្យរដ្ឋបាលព្រៃឈើបង្កើត និងប្រើប្រាស់គំរូសំណបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ ដែលមានរាងមូលសំប៉ែតមានវិជ្ឈមាត្រ ៤០មម និងកំរាស់ ៥មម ។ សំណបិទភ្ជិតនេះ បន្ទាប់ពីបានកិបបិទភ្ជិតលើខុនថៃនណឺដោយដង្កាប់កិបរួចមក នឹងលេចចេញនូវរូបភាពជាសញ្ញាសំគាល់មានទំរង់ដូចរាងនៃសញ្ញាសំគាល់របស់រដ្ឋបាលព្រៃឈើ និងនៅលើផ្ទៃម្ខាងផ្នែកខាងមុខមានបង្ហាញអក្សរកាត់ថា **រ.ព** ស្ថិតនៅចំកណ្តាល និងនៅពីក្រោមមានលេខសំគាល់ ០១ ឬ ០២ រហូតដល់លេខ ០៩ និងនៅលើផ្ទៃម្ខាងទៀតផ្នែកខាងក្រោយមានសញ្ញាសំគាល់ដោយរូបដើមឈើមួយដើមនៅចំកណ្តាល ព្រមទាំងមានអមដោយញញួរត្រារដ្ឋបាលព្រៃឈើចំនួនពីរ ដាក់ខ្វែងគ្នាស្ថិតនៅផ្នែកគល់នៃដើមឈើ ដូចមានកំណត់ក្នុង ***ឧបសម្ព័ន្ធទី ១*** នៃប្រកាសនេះ ។

**ប្រការ ៣ :** រាល់ផល អនុផលព្រៃឈើនាំចេញដែលផ្ទុកក្នុងខុនថៃនណឺ ចាំបាច់ត្រូវមានការត្រួតពិនិត្យ និងបិទសំណភ្ជិតជាមុន ដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅមុនពេលអនុញ្ញាតដឹកជញ្ជូនទៅកាន់ឃ្លាំង ឬទីលានបញ្ចេញទំនិញពីគយ ។

ខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ គឺសំដៅទៅលើសំបកធុងគ្រប់ប្រភេទ ដែលអាចផ្ទុកផល អនុផលព្រៃឈើ ស្របតាមស្តង់ដា ដោយធានាគុណភាព និងសុវត្ថិភាព ។

**ប្រការ ៤ :** មន្ត្រីរដ្ឋបាលព្រៃឈើដែលមានសមត្ថកិច្ចចុះត្រួតពិនិត្យ និងបិទសំណភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ ត្រូវធ្វើកំណត់ហេតុស្របតាមគំរូ ដូចបានកំណត់ក្នុង ***ឧបសម្ព័ន្ធទី ២*** នៃប្រកាសនេះ ។

ការត្រួតពិនិត្យ និងបិទសំណភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ អាចប្រព្រឹត្តទៅបានលុះត្រាតែមានអាជ្ញាប័ណ្ណនាំចេញ ដែលមានចុះទិដ្ឋាការដោយរដ្ឋបាលព្រៃឈើ ឬមានគោលការណ៍អនុញ្ញាតនាំចេញរបស់រាជរដ្ឋាភិបាលហើយត្រូវមានលិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើ នាំចេញ ដែលផ្តល់ដោយប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៥ :** ការស្នើសុំកាត់ចេញនូវសំណដែលបានបិទភ្ជិតរួច ដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ ដើម្បីធ្វើការត្រួតពិនិត្យឡើងវិញដោយមូលហេតុណាមួយចាំបាច់ អាចប្រព្រឹត្តទៅបានលុះត្រាមានការអនុញ្ញាតពីប្រធានរដ្ឋបាលព្រៃឈើ ឬរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**ប្រការ ៦ :** ការផ្ទុក និងដឹកជញ្ជូននាំចេញផល អនុផលព្រៃឈើតាមខុនថៃនណឺ ដោយពុំមានការត្រួតពិនិត្យ និងបិទសំណភ្ជិតជាមុនពីមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ឬមានកិបសំណបិទភ្ជិតដែលខុសពីនីតិវិធីរបស់រដ្ឋបាលព្រៃឈើ ត្រូវចាត់ទុកជាល្មើសច្បាប់ ។

ក្នុងករណីសំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ មានភាពមិនប្រក្រតីដូចជា បែក បាក់ ឬ ដាច់ ដែលមានមូលហេតុច្បាស់លាស់ ម្ចាស់ទំនិញចាំបាច់ត្រូវរាយការណ៍មកមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច នៅនឹងកន្លែងជាបន្ទាន់ ដើម្បីសុំវិធានការពីប្រធានរដ្ឋបាលព្រៃឈើ ។

**ប្រការ ៧ :** ជនណាមានចេតនាធ្វើឱ្យខូច ដាច់ ឬ បែកបាក់សំណាបិទភ្ជិតដែលកឹបរូចលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញដោយរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ក្នុងគោលបំណងផ្លាស់ប្តូរ ឬ បន្ថែមទំនិញផ្ទុយពីអាជ្ញាប័ណ្ណនាំចេញ ឬ លិខិតអនុញ្ញាតដឹកជញ្ជូននាំចេញ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៨ :** ជនណាបង្កើត ប្រើប្រាស់ ឬ ក្លែងបន្លំសំណាបិទភ្ជិត លើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ ត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

**ប្រការ ៩ :** អគ្គនាយកនៃក្រសួង អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធានរដ្ឋបាលព្រៃឈើ និង ប្រធានអង្គភាពពាក់ព័ន្ធនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធិភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៤ ខែ កុម្ភៈ ឆ្នាំ ២០០៥

រដ្ឋមន្ត្រី

ច័ន្ទ សារុន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងការពារជាតិ
- ក្រសួងសេដ្ឋកិច្ច-ហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ខុទ្ទកាល័យនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត-ក្រុង
- ទីចាត់ការគយ និងរដ្ឋាករ
- នាយកដ្ឋានកម្ពុជាត្រួតពិនិត្យទំនិញ ទីហរ៍ណ អាហរ៍ណ និងបង្ក្រាបការក្លែងបន្លំ ( កាំកុងត្រូលកម្ពុជា)
- ដូចប្រការ ៩
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធទី ១ ភ្ជាប់ប្រកាសលេខ....៨៥៧ ប្រក....ចុះថ្ងៃទី ១៤ ខែ ធ្នូ ឆ្នាំ ២០០៤

## សញ្ញាសំគាល់សំណបិទត្រឹតលើកុងតឺន័រផ្ទុក
## ផល អនុផលព្រៃឈើនាំចេញបន្ទាប់ពីកៀបដោយដង្កាប់




សញ្ញាសំគាល់ផ្ទៃម្ខាងផ្នែកខាងមុខ



សញ្ញាសំគាល់ផ្ទៃម្ខាងផ្នែកខាងក្រោយ

ឧបសម្ព័ន្ធទី ២ ភ្ជាប់ប្រកាសលេខ..១៩០ ប្រ.កសក.. ចុះថ្ងៃទី ២៤ ខែ ..កុម្ភៈ.. ឆ្នាំ ២០០៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាលព្រៃឈើ**

**កំណត់ហេតុ**

**ស្តីពី**

**ការត្រួតពិនិត្យ និងកិបសំណាបិទភ្ជិត**

**លើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ**

ឆ្នាំ.................................... ខែ............ ថ្ងៃទី................វេលាម៉ោង......................

នៅទីតាំង..........................................................................................មានការត្រួតពិនិត្យ និងកិបសំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញរបស់លោក/លោកស្រី.................................. ជាប្រធាន/តំណាង....................................................................ធ្វើឡើងដោយមន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ច ដែលមានសមាសភាពចូលរួម និងទទួលបានលទ្ធផលដូចខាងក្រោម:

### ១.សមាសភាពមន្ត្រីរដ្ឋបាលព្រៃឈើចូលរួមត្រួតពិនិត្យ

-លោក..............................................

-..............................................

-..............................................

-..............................................

### ២.ម្ចាស់ ឬតំណាងម្ចាស់ផល អនុផលព្រៃឈើចូលរួម

-លោក..............................ប្រធាន/តំណាងក្រុមហ៊ុន...................................

-..........................................................................

-..........................................................................

-..........................................................................

### ៣.លទ្ធផលនៃការត្រួតពិនិត្យ និងកិបសំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញ

១.-ខុនថៃនណឺលេខ..........................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ.......................................................................................................

-យថាប្រភេទ.........................................................................................................................

-បរិមាណ.............................................................................................................................

-កីបសំណាបិទភ្ជិតលេខ រ.៣...................... ។

២.-ខុនថៃនណឺលេខ........................................................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ.......................................................................................................

-យថាប្រភេទ.........................................................................................................................

-បរិមាណ.............................................................................................................................

-កីបសំណាបិទភ្ជិតលេខ រ.៣...................... ។

៣.-ខុនថៃនណឺលេខ........................................................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ. ....................................... ..............................................

-យថាប្រភេទ.........................................................................................................................

-បរិមាណ.............................................................................................................................

-កីបសំណាបិទភ្ជិតលេខ រ.៣...................... ។

៤.-ខុនថៃនណឺលេខ........................................................................................................................

-ផ្ទុកផល អនុផលព្រៃឈើប្រភេទ.......................................................................................................

-យថាប្រភេទ.........................................................................................................................

-បរិមាណ.............................................................................................................................

-កីបសំណាបិទភ្ជិតលេខ រ.៣...................... ។

សរុបខុនថៃនណឺដែលបានត្រួតពិនិត្យ និងកីបសំណាបិទភ្ជិត មានចំនួន.................................... ខុនថៃនណឺ

សរុបផល អនុផលព្រៃឈើដែលបានផ្ទុកមានបរិមាណ.................................................................................។

### ៥.ការបញ្ជាក់ធានារបស់ម្ចាស់ផល អនុផលព្រៃឈើនាំចេញ

ខ្ញុំបាទ នាងខ្ញុំ សូមធានាថាមិនធ្វើឱ្យខូចខាត បែកបាក់ ឬដាច់ សំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផល អនុផលព្រៃឈើនាំចេញរបស់រដ្ឋបាលព្រៃឈើក្នុងគោលបំណងផ្លាស់ប្តូរ ឬបន្ថែមទំនិញផ្ទុយពីលិខិតអនុញ្ញាតនាំចេញឡើយ ។ ក្នុងករណី ខ្ញុំបាទ នាងខ្ញុំ ប្រព្រឹត្តផ្ទុយពីការធានាខាងលើនេះ ខ្ញុំបាទ នាងខ្ញុំ សូមទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ។

ការត្រួតពិនិត្យ និង កីបសំណាបិទភ្ជិតលើខុនថៃនណឺផ្ទុកផលអនុផលព្រៃឈើនាំចេញរបស់លោក/លោកស្រី.............

.................................. ប្រធាន/តំណាងក្រុមហ៊ុន ......................................................................................

បានអនុវត្តចប់សព្វគ្រប់នៅវេលាម៉ោង ............................ នាថ្ងៃទី............ខែ............ ឆ្នាំ.................. ។

**លិខិតភ្ជាប់** :-អាជ្ញាប័ណ្ណនាំចេញលេខ............ ពកប.ន ចុះថ្ងៃទី ........ ខែ..........ឆ្នាំ ........ ។

-លិខិតគោលការណ៍អនុញ្ញាតនាំចេញផល អនុផលព្រៃឈើលេខ.................................... ចុះថ្ងៃទី ........ ខែ..........ឆ្នាំ ..........

-លិខិតអនុញ្ញាតដឹកជញ្ជូនផល អនុផលព្រៃឈើនាំចេញលេខ.................................. ចុះថ្ងៃទី ........... ខែ..........ឆ្នាំ ..........

-បញ្ជីផល អនុផលព្រៃឈើនាំចេញ ។

**អ្នកធ្វើកំណត់ហេតុ**

**ម្ចាស់ផល អនុផលព្រៃឈើនាំចេញ**

**មន្ត្រីរដ្ឋបាលព្រៃឈើមានសមត្ថកិច្ចត្រួតពិនិត្យ**

បានឃើញ និងបញ្ជូនមក

លោកប្រធានរដ្ឋបាលព្រៃឈើ

"ដើម្បីមេត្តាពិនិត្យ សំរេច"

រាជធានីភ្នំពេញ, ថ្ងៃទី........ខែ...........ឆ្នាំ ... . .....

**ប្រធានការិយាល័យអភិវឌ្ឍន៍ឧស្សាហកម្ម និងពាណិជ្ជកម្មព្រៃឈើ**

បានឃើញ និងឯកភាព

រាជធានីភ្នំពេញ, ថ្ងៃទី.........ខែ...........ឆ្នាំ ...........

**ប្រធានរដ្ឋបាលព្រៃឈើ**